សរសេរ ជាភាសាបារាំងថា UNIVERSITE ROYALE D'AGRICULTUE ( U.R.A ) ដែលស្ថិតនៅក្រោម ការគ្រប់គ្រងផ្ទាល់ របស់ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និង នេសាទ ។

មាត្រា ២ .. តួនាទី ភារកិច្ច រចនាសម្ព័ន្ធរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម ត្រូវកំណត់ឡើងវិញអោយបានសមស្រប ។

មាត្រា ៣ .. បទបញ្ញត្តិទាំងឡាយណាដែលមានពីមុនមក ហើយផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ .. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អនុរដ្ឋលេខាធិការមុខងារសាធារណៈ និង សាកលវិទ្យាល័យធិការ នៃសាកលវិទ្យាល័យ ភូមិន្ទកសិកម្មមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងខ្លួនៗ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ០៨ អនក្រ

រាជរដ្ឋាភិបាលកម្ពុជា

_ បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_ បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៣ របស់រាជរដ្ឋាភិបាលស្តីពីការតំលើងប្រាក់បៀវត្ស ២០ ភាគរយលើបៀវត្សសុទ្ធសាធជូនមន្ត្រីរាជការ កងទ័ព និង នគរបាល

_ តាមសំណើរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១** .. តំលើងប្រាក់បៀវត្ស ២០ ភាគរយលើបៀវត្សសុទ្ធសាធជូន ជនពិការ និង និវត្តជន ។

**មាត្រា ២** .. ប្រាក់បៀវត្សដែលតំលើង ២០ ភាគរយនេះ ត្រូវអនុវត្តពីបៀវត្ស ខែ មិនា ឆ្នាំ ១៩៩៤ តទៅ ។

**មាត្រា ៣** .. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង អភិបាលគ្រប់ខេត្ត ក្រុងត្រូវ ទទួលអនុវត្តអនុក្រឹត្យនេះ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ០៩ អនក្រ

### ស្តីពីការបង្កើតសេនាធិការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ សៀមរាប . បន្ទាយមានជ័យ. បាត់ដំបង.កំពង់ចាម និង ក្រុងព្រះសីហនុ

រាជរដ្ឋាភិបាលកម្ពុជា

_ បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃ ព្រះរាជរដ្ឋបាលកម្ពុជា